ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 06 / 2011
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង Natacha WEXELS-RISER

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជា លាង (សហព្រះរាជអាជ្ញា), លោក Andrew Cayley (សហព្រះរាជអាជ្ញា), លោក ចាន់ដារ៉ា រស្មី (សហព្រះរាជអាជ្ញារង),លោក William Smith (សហព្រះរាជអាជ្ញារង), លោក ពេជ្រ សម្បត្តិ (ជំនួយការជាន់ខ្ពស់), លោក ផាន់ សុជា (ក្រឡាបញ្ជី), លោក ជា ផល្លា (អ្នកស៊ើបអង្កេត) |
| ជនជាប់ចោទ៖ លោក នួន ជា (ព្រឹក), លោក អៀង សារី, លោកស្រី អៀង ធីរិទ្ធ (ព្រឹក), លោក ខៀវ សំផន |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អារុណ (សហមេធាវី), លោក Michiel Pestman (សហមេធាវី), លោក Victor Koppe (សហមេធាវី), លោក Andrew Ianuzzi (ទីប្រឹក្សាច្បាប់), លោក Jasper Pauw (ទីប្រឹក្សាច្បាប់), លោក ព្រំ ផល្លា (អ្នកគ្រប់គ្រងសំណុំរឿង), កញ្ញា Annebrecht Vossenberg (ទីប្រឹក្សាច្បាប់)។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម (សហមេធាវី), លោក Michael G. Garnavas (សហមេធាវី), កញ្ញា Tanya Pettay (ទីប្រឹក្សាច្បាប់), លោក Neville Sorab (ទីប្រឹក្សាច្បាប់), លោក សូ មូស្សេទ្ធី (អ្នកគ្រប់គ្រងសំណុំរឿង), លោក Joshua Kern (ទីប្រឹក្សាច្បាប់)។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង ធីរិទ្ធ៖ លោក ផាត់ ពៅស៊ាង (សហមេធាវី), កញ្ញា Karlijn Van der Voort (ទីប្រឹក្សាច្បាប់), លោក ខាន់ សេរីវុទ្ធី (អ្នកគ្រប់គ្រងសំណុំរឿង), កញ្ញា Vera Mannuello(ទីប្រឹក្សាច្បាប់)។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក សរ សូវាន (សហមេធាវី), លោក Jacques Verges (សហមេធាវី), លោកស្រី សេង សុជាតា (អ្នកគ្រប់គ្រងសំណុំរឿង), កញ្ញា Marie Capotorto (ទីប្រឹក្សាច្បាប់), កញ្ញា Shéhérazade Bouarfa (ទីប្រឹក្សាច្បាប់)។ |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ (សហមេធាវីនាំមុខ), លោកស្រី Elisabeth Simonneau-Fort (សហមេធាវីនាំមុខ), លោកស្រី ម៉ុច សុវណ្ណារី,លោកស្រី Martine Jacquin, លោកស្រី Silke Stuzinsky , លោក Olivier Bahougne, លោកស្រី Lyma Nguyen , លោក Pascal Aubouin, លោកស្រី Christine Martineau, លោកស្រី Fabienne Trusse-Naprous, លោកស្រី Philipine Sutz, លោក ហុង គឹមសួន, លោក Emanuel Jacomy |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោកស្រី Julie Massé, លោក ណុល ដារ៉ា, លោក សាន គីរី, លោកស្រី Franziska Charlotte ECKELMANS, លោកស្រី Susan LAMB, លោក Zhao LONG, លោក Joshua Rosensweig, លោក Ulrich Forster. |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.២៥ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៤.០៥ |

| ចំនួនម៉ោងសរុបរបស់តុលាការៈ ៤ ម៉ោង និង ៤០ នាទី |
|---|

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការទទួលស្គាល់មេធាវីអន្តរជាតិ | មេធាវីការពារឲ្យ ខៀវ សំផន និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.០៥ | ៩.២០ |
| ការប្រកាសអំពីចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង និងបញ្ហាពាក់ព័ន្ធផ្សេងៗ | អង្គជំនុំជម្រះ | ៩.២០ | ១០.០៧ |
| សំណើសុំផ្សេងៗ និងមតិយោបល់ | មេធាវីការពារឲ្យ នួន ជា | ៩.២៣ | ៩.៤១ |
| ការប្រកាសអំពីសវនាការនាពេលខាងមុខ | អង្គជំនុំជម្រះ | ១០.០៧ | ១០.២២ |
| សំណើសុំធ្វើការឆ្លើយតបទៅមេធាវីការពារឲ្យ នួន ជា | សហព្រះរាជអាជ្ញា | ១០.៥០ | ១០.៥១ |
| សំណើសុំការអនុញ្ញាតិឲ្យ លោកស្រី អៀង ធីរិទ្ធ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ | មេធាវីការពារឲ្យ អៀង ធីរិទ្ធ | ១០.៥១ | ១០.៥៣ |
| សំណើសុំឲ្យធ្វើការបញ្ជាក់ទៅលើបញ្ជីឈ្មោះសាក្សី | មេធាវីការពារឲ្យ នួន ជា | ១០.៥៣ | ១០.៥៨ |
| សំណើសុំចាកចេញទៅបន្ទប់ទឹក | មេធាវីការពារឲ្យ ខៀវ សំផន | ១០.៥៨ | ១១.០៣ |
| អញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង | មេធាវីការពារឲ្យ អៀង សារី | ១១.០៦ | ១១.៥៧ |
| ការពិភាក្សាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ | អង្គជំនុំជម្រះ | ១៤.០៥ | ១៤.៥១ |
| ការឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារឲ្យ នួន ជា | សហព្រះរាជអាជ្ញា | ១៤.៥៧ | ១៥.០៤ |

| | | | |
|---|---|---|---|
| ការឆ្លើយតបទៅនឹងអញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង | សហព្រះរាជអាជ្ញា | ១៥.០៥ | ១៥.៤៣ |
| សំណើសុំឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី និង Martine Jacquin ធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងអញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៥.៤៤ | ១៦.០៩ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះសាលាដំបូងប្រកាសបើកសវនាការ។

**<u>ការទទួលស្គាល់មេធាវីអន្តរជាតិ (វិធាន ២២ អនុវិធាន ២ ចំណុច ក)</u>**

លោក Jacques VERGÈS ត្រូវបានណែនាំខ្លួនដោយសហមេធាវីជាតិ ហើយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ដំណើរការនីតិវិធី។

លោកស្រី Ms. Lyma NGUYEN, លោក Mr. Olivier BAHOUGNE, លោក Emmanuel JACOMY, លោក Philippine SUTZ, លោកស្រី Silke STUDZINSKY, លោក Pascal AUBOIN, លោកស្រី Martine JACQUIN, លោកស្រី Fabienne TRUSSES, លោកស្រី Christine MARTINEAU ត្រូវបានណែនាំខ្លួនដោយសហមេធាវីនាំមុខជាតិតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់ដំណើរការនីតិវិធី។

**<u>ការប្រកាសអំពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង</u>**

អង្គជំនុំជម្រះបានផ្តល់នូវបញ្ជីឈ្មោះសម្ងាត់នៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទៅឱ្យភាគី។

**<u>សំណើផ្សេងៗដែលបានលើកឡើងដោយមេធាវីការពារឱ្យ នួន ជា</u>**

មេធាវីការពារឱ្យ នួន ជា បានស្នើសុំការអនុញ្ញាតិឱ្យលោក នួន ជា ពាក់មួក និងវ៉ែន តាខ្មៅ និងស្នើសុំបន្ថែមកៅអីមួយទៀតសម្រាប់សហមេធាវីអន្តរជាតិ។ សំណើពីរដំបូងត្រូវបានអនុញ្ញាតិដោយអង្គជំនុំជម្រះ ដោយឡែកសំណើទី៣ អង្គជំនុំជម្រះនឹងពិចារណាក្នុងពេលវេលាសមស្រប។ មេធាវីការពារឱ្យ នួន ជា បានលើកឡើងថា ការស៊ើបអង្កេតមិនមានលក្ខណៈយុត្តិធម៌សម្រាប់

លោកនួន ជា នោះទេ និងស្នើឲ្យសាក្សីទាំងអស់ដែលពួកគេបានស្នើសុំ ត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម។

លោក នួន ជា បានស្នើសុំចាកចេញពីបន្ទប់សវនាការ និងបានបញ្ជាក់ថាគាត់នឹងត្រឡប់មកបន្ទប់សវនាការវិញនៅពេលដែលអង្គជំនុំជម្រះពិចារណាអំពីសំណើរបស់គាត់។

<u>ការប្រកាសអំពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (បន្ត)</u>

អង្គជំនុំជម្រះបានសួរទៅភាគីថា នៅពេលដែលបញ្ជីឈ្មោះបណ្តោះអាសន្ន នឹងត្រូវយកមកពិភាក្សាថាតើភាគីមានបំណងជំទាស់ទៅនឹងការពិភាក្សាអំពីបញ្ជីឈ្មោះសាក្សីនៅក្នុងសវនាការជាសាធារណៈ ឬស្នើសុំឲ្យធ្វើសវនាការជាអសាធារណៈនៅថ្ងៃចុងក្រោយនៃសវនាការបឋមនេះ ។

សហមេធាវីនាំមុខអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំនូវឱកាសក្នុងការពន្យល់អំពីមូលហេតុដែលបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានដាក់មកចំពោះមុខអង្គជំនុំជម្រះ។

អង្គជំនុំជម្រះបានបង្ហាញថាបញ្ហាទាំងអស់នេះនឹងត្រូវលើកយកមកពិភាក្សានៅថ្ងៃចុងក្រោយនៃសវនាការបឋម។

មេធាវីការពារឲ្យ អៀង សារី បានស្នើសុំថាការពិភាក្សាទៅលើបញ្ជីឈ្មោះសាក្សីគួរត្រូវបានធ្វើនៅក្នុងសវនាការជាសាធារណៈ ដោយមិនប្រកាសឈ្មោះសាក្សីទាំងនោះ។

មេធាវីការពារឲ្យ ខៀវ សំផន បានស្នើសុំឲ្យធ្វើការពិភាក្សានៅក្នុងសវនាការជាអសាធារណៈ ដោយសារតែសាក្សីខ្លះមិនទាន់មានឈ្មោះរហស្សនាម។

សហព្រះរាជអាជ្ញាយល់ព្រមឲ្យមានការពិភាក្សាអំពីបញ្ជីឈ្មោះសាក្សីនៅក្នុងសវនាការជាសាធារណៈ ដោយប្រើប្រាស់ឈ្មោះរហស្សនាម។

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានការជំទាស់ចំពោះការពិភាក្សាអំពីបញ្ជីឈ្មោះសាក្សីនៅក្នុងសវនាការជាសាធារណៈនោះទេ និងបានបង្ហាញថាពួកគេនឹងដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានកាត់បន្ថយបន្ថែមទៀតសម្រាប់កោះហៅមកផ្តល់សក្ខីកម្ម នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១។

<u>ការប្រកាសអំពីសវនាការនាពេលខាងមុខ</u>

អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីអំពីការធ្វើសវនាការទាក់ទងនឹងបញ្ហាផ្សេងៗដែលរួមមានសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។ ប្រសិនបើអង្គជំនុំជម្រះយល់ថាចាំបាច់

ត្រូវមានកិច្ចសវនាការបន្ថែមពាក់ព័ន្ធនឹងសម្បទារបស់ជនជាប់ចោទ កាលបរិច្ឆេទនៃសវនាការនេះ ទំនងជាប្រព្រឹត្តទៅនៅខែ សីហា ឆ្នាំ ២០១១។

មេធាវីការពារឲ្យ អៀង ធីរិទ្ធ ជំទាស់ទៅនឹងការដាក់របាយការណ៍របស់អ្នកជំនាញ ដែលនឹងចាត់ថ្នាក់ជាឯកសារសម្ងាត់នៅក្នុងសំណុំរឿង។

មេធាវីការពារឲ្យ អៀង សារី ស្នើសុំពេលវេលាបន្ថែមក្នុងការឆ្លើយតបទៅនឹងញត្តិរបស់សហព្រះរាជអាជ្ញា ហើយក៏បានស្នើសុំឲ្យកំណត់កាលបរិច្ឆេទផុតកំណត់ ដោយមិនឲ្យមានការដាក់បញ្ហាយុត្តាធិការ។

សហព្រះរាជអាជ្ញាស្នើសុំឲ្យរក្សានូវពេលវេលាកំណត់សម្រាប់ការឆ្លើយតបទៅនឹងញត្តិរបស់ពួកគេ

<u>សំណើសុំការអនុញ្ញាតិឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ</u>

មេធាវីការពារឲ្យ អៀង ធីរិទ្ធ បានស្នើសុំការអនុញ្ញាតិឲ្យ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ។ អង្គជំនុំជម្រះទទួលយកសំណើនេះ។

<u>សំណើឲ្យមានការបញ្ជាក់ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី</u>

មេធាវីការពារឲ្យ នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់អំពីបញ្ជីឈ្មោះសាក្សីដែលត្រូវពិភាក្សានៅថ្ងៃចុងក្រោយនៃសវនាការបឋមនេះ។

<u>សំណើសុំឲ្យលោក ខៀវ សំផន ចាកចេញទៅបន្ទប់ទឹក</u>

មេធាវីការពារឲ្យ ខៀវ សំផន បានស្នើសុំការអនុញ្ញាតិឲ្យ ជនជាប់ចោទ ខៀវ សំផន ចាកចេញទៅបន្ទប់ទឹក។ អង្គជំនុំជម្រះទទួលយកសំណើនេះ។

<u>អញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង</u>

មេធាវីការពារឲ្យ អៀង សារី បានធ្វើសេចក្តីសន្និដ្ឋានអំពីអញ្ញត្រកម្មរបស់ពួកគេស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង។

<u>ការពិភាក្សាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ</u>

អង្គជំនុំជម្រះបានរំលឹកអំពីវិធាន ៨១ អនុវិធាន ៣,៤,៥ និងបានចង្អុលបង្ហាញថា វត្តមានរបស់ជនជាប់ចោទគឺតម្រូវឲ្យមាននៅពេលដំណើរការនីតិវិធី។ អង្គជំនុំជម្រះអាចអនុញ្ញាតិឲ្យជនជាប់ចោទអវត្តមានពីបន្ទប់សវនាការបាន អាស្រ័យទៅលើមូលហេតុដែលបានស្នើសុំ។ បន្ទាប់មកជនជាប់ចោទអាចបន្តតាមដានដំណើរការនីតិវិធីពីបន្ទប់រង់ចាំខាងក្រោម។

មេធាវីការពារឱ្យ ខៀវ សំផន បានស្នើសុំការអនុញ្ញាតិឱ្យជនជាប់ចោទ ខៀវ សំផន បន្តតាមដានដំណើរការនីតិវិធីពីបន្ទប់រង់ចាំខាងក្រោម ដើម្បីរក្សាកំលាំងដើម្បីចូលរួមសវនាការនៅថ្ងៃបន្ទាប់។ អង្គជំនុំជម្រះបានបដិសេធសំណើសុំនេះ។

មេធាវីការពារឱ្យ អៀង សារី បានស្នើសុំការអនុញ្ញាតិឱ្យជនជាប់ចោទ អៀង សារី បន្តតាមដានដំណើរការនីតិវិធីពីបន្ទប់រង់ចាំខាងក្រោម ដោយសារតែគាត់ឈឺចង្កេះ។ អង្គជំនុំជម្រះទទួលយកសំណើសុំនេះ។

អង្គជំនុំជម្រះបានចង្អុលបង្ហាញថា ជនជាប់ចោទត្រូវតែមកបន្ទប់សវនាការជារៀងរាល់ព្រឹក។ ប្រសិនបើជនជាប់ចោទមានបំណងចង់តាមដានដំណើរការនីតិវិធីពីបន្ទប់រង់ចាំខាងក្រោម ជនជាប់ចោទអាចស្នើសុំដោយមានមូលហេតុបញ្ជាក់ឱ្យបានច្បាស់លាស់។

<u>ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះអញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង</u>

សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានតបចំពោះអញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង។

<u>ការឆ្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំពោះអញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង</u>

សហមេធាវីនាំមុខ បានស្នើសុំឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី និងMartine Jacquin ធ្វើសេចក្តីសន្និដ្ឋានតបក្នុងនាមពួកគេ។ សំណើនេះត្រូវបានទទួលយក ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើសេចក្តីសន្និដ្ឋានតបចំពោះអញ្ញត្រកម្មស្តីពីគោលការណ៍គ្មានការកាត់ទោសពីរដង។

<u>**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**</u>

- បង្គាប់ឱ្យនាំជនជាប់ចោទ អៀង ធីរិទ្ធ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង និងបង្គាប់ឱ្យអង្គភាពសោតទស្សន៍ភ្ជាប់បណ្តាញវីដេអូទៅមន្ទីរឃុំឃាំង ដើម្បីឱ្យគាត់អាចតាមដានដំណើរការនីតិវិធីបាន (១០.៥១)។
- បង្គាប់ឱ្យនាំជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់រង់ចាំខាងក្រោម និងបង្គាប់ឱ្យអង្គភាពសោតទស្សន៍ភ្ជាប់បណ្តាញវីដេអូទៅបន្ទប់រង់ចាំខាងក្រោម (១៤.៤៩)។
- បង្គាប់ឱ្យនាំជនជាប់ចោទត្រឡប់ទៅកាន់មន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃទី

| |
|---|
| ២៨ ខែ មិថុនា ឆ្នាំ ២០១១។ |

| |
|---|
| ដីកាសម្រាប់ការលើកវារកាលសវនាការ |
| សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ វេលាម៉ោង ៩.០០ ព្រឹក ។ |

ភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលទុំ Natacha WEXELS-RISER